ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៤៥ គ.ជ.ប

គោលការណ៍
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅ នៃកម្មវិធីផ្សាយគោលនយោបាយ
របស់គណបក្សនយោបាយ

- អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

១. គោលបំណង

កម្មវិធីផ្សាយគោលនយោបាយរបស់គណបក្ស ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីឱ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមភូមិភាគ ហើយដែលបានទទួលស្គាល់ជាផ្លូវការដោយ គ.ជ.ប មានឱកាសធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់អ្នកបោះឆ្នោត សម្រាប់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ។

២. ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយ

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ សម្រាប់ចាក់ផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ដែលរៀបចំឡើងដោយ គ.ជ.ប មានដូចខាងក្រោម ៖

- ២.១ កម្មវិធីឆ្លើយសំណួរទៅតាមប្រធានបទដែលកំណត់ដោយ គ.ជ.ប ។
- ២.២ កម្មវិធីចាក់ផ្សាយស្ប៉ត (Spot) ដែលផលិតដោយសាមីគណបក្សនយោបាយតាមវិទ្យុ និងទូរទស្សន៍ ។
- ២.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬរបស់ថ្នាក់ដឹកនាំគណបក្សនយោបាយនៅលើព្រឹត្តិបត្រគោលនយោបាយគណបក្ស ដែលបោះពុម្ពផ្សាយដោយ គ.ជ.ប ។

ការរៀបចំកម្មវិធីទាំង ៣ (បី) ខាងលើ ត្រូវស្ថិតក្រោមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្របសម្រួល ដែលសម្រេចដោយ គ.ជ.ប ។

៣. ការអនុវត្តគោលការណ៍

ការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ត្រូវអនុវត្តតាមគោលការណ៍ស្មើភាព ដោយគណបក្សនយោបាយនីមួយៗ ទទួលបានម៉ោងផ្សាយតាមវិទ្យុជាតិ និងទូរទស្សន៍ជាតិកម្ពុជា ក្នុង ១ (មួយ) ថ្ងៃ រយៈពេល ១៥នាទី ហើយរយៈពេលនេះនឹងត្រូវចាក់ផ្សាយឡើងវិញក្នុងថ្ងៃដដែល ។

៤. ការទទួលខុសត្រូវរបស់គណបក្សនយោបាយ

គណបក្សនយោបាយ ត្រូវគោរពតាមការរៀបចំ និងចាត់ចែងដោយគណៈកម្មការសម្របសម្រួលដែលរៀបចំការចាប់ឆ្នោតយកលំដាប់លេខរៀងមុនក្រោយសម្រាប់ការថត ទីកន្លែងអង្គុយ ម៉ោងផ្សាយ និងគោរពបទបញ្ជាសម្រាប់ថតកម្មវិធី ។

គណបក្សនយោបាយដែលចូលរួមក្នុងកម្មវិធីផ្សាយគោលនយោបាយ ត្រូវតែគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ និងគោរពតាមគោលការណ៍នេះ ។

៥. ការទទួលខុសត្រូវខ្លឹមសារផ្សព្វផ្សាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ជាអ្នកទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ដែលរៀបចំឡើងដោយ គ.ជ.ប ហើយត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ៕

ថ្ងៃអង្គារ ១៤ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៨
ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ស៊ឹក ប៊ុនហុក